## សូមស្វែងយល់អំពីរបៀបការពារជីវិតរបស់អ្នក និងការជម្លៀសខ្លួនឱ្យបានត្រឹមត្រូវ។

**ទោះបីជាការរាតត្បាតនៃជំងឺបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មី (កូវីដ 19)**
**នៅមិនទាន់មានការថមថយក៏ដោយ**

***តែនៅពេលមានគ្រោះមហន្តរាយកើតឡើង តាមគោលការណ៍***
***អ្នកត្រូវតែជម្លៀសខ្លួនចេញពីកន្លែងគ្រោះថ្នាក់។***

# 5 ចំណុចដែលអ្នកគួរយល់ដឹង

- ការជម្លៀសមានន័យថាជាការគេចខ្លួនចេញពីគ្រោះថ្នាក់។ **ប្រសិនបើអ្នកស្ថិតនៅកន្លែងមានសុវត្ថិភាពហើយ អ្នកមិនចាំបាច់ទៅជម្រកសម្រាប់ការជម្លៀសខ្លួនឡើយ។**
- ជម្រើសសម្រាប់កន្លែងសុវត្ថិភាពមិនមែនមានតែសាលាបឋមសិក្សា និងវិទ្យាល័យ ឬមជ្ឈមណ្ឌលសហគមន៍នោះទេ។ អ្នកក៏អាច**ជម្លៀសខ្លួនទៅកាន់ផ្ទះរបស់សាច់ញាតិ ឬផ្ទះមិត្តភក្តិបានផងដែរ ប្រសិនទីនោះមានសុវត្ថិភាព។**
- នៅពេលនោះពុំមាន **ម៉ាស ទឹកលាងដៃសម្លាប់មេរោគ និងឧបករណ៍វាស់កម្តៅ។** ដូច្នេះសូម**យករបស់របរផ្ទាល់ខ្លួន**ទៅជាមួយឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- **មជ្ឈមណ្ឌលសម្រាប់ការជម្លៀសដែល**បានកំណត់ដោយអាជ្ញាធរមូលដ្ឋានរបស់អ្នក **អាចមានការផ្លាស់ប្តូរ ឬមានចំនួនមនុស្សកើនឡើងច្រើន។** ក្នុងគ្រាមានគ្រោះមហន្តរាយ ត្រូវប្រាកដថា**អ្នកបានតាមដានមើលវែបសាយត៍អាជ្ញាធរក្នុងមូលដ្ឋានរបស់អ្នក ។ល។**
- ការចេញក្រៅក្នុងពេលកំពុងមានភ្លៀងធ្លាក់ខ្លាំងគឺ**មានគ្រោះថ្នាក់ សូម្បីតែនៅក្នុងរថយន្តក៏ដោយ។** ប្រសិនបើអ្នកជៀសមិនរួច**ត្រូវតែនៅក្នុងរថយន្តមួយយប់ចូរពិនិត្យមើលនៅជុំវិញខ្លួនអ្នកដោយប្រុងប្រយ័ត្ន**ដើម្បីជៀសវាងកុំជាប់នៅក្នុងទឹកជំនន់។

ការិយាល័យខុទ្ទកាល័យ (គ្រប់គ្រងគ្រោះមហន្តរាយ)
និង ភ្នាក់ងារគ្រប់គ្រងអគ្គិភ័យ និងគ្រោះមហន្តរាយ



# ឥឡូវដល់ពេល ដែលត្រូវពិនិត្យមើលថាតើ ផ្ទះរបស់អ្នកមានសុវត្ថិភាពឬអត់!

## តារាងលំហូរអំពីការសម្រេចចិត្តជម្លៀស

**ចាប់ផ្តើម!**

## តើអ្នកគួរធ្វើដូចម្តេចដើម្បីជម្លៀស?

ស្វែងរក និងគូសចំណាំទីតាំងផ្ទះរបស់អ្នកនៅលើផែនទីគ្រោះថ្នាក់*

* ផែនទីគ្រោះថ្នាក់ គឺជាផែនទីដែលមានកំណត់ពណ៌លើតំបន់ដែលមានហានិភ័យគ្រោះមហន្តរាយខ្ពស់ ដូចជា ទឹកជំនន់ ឬការបាក់ដី។ ប៉ុន្តែ គ្រោះមហន្តរាយក៏អាចកើតឡើងនៅក្នុងតំបន់ដែលមិនមានដាក់ពណ៌ដែរ។

តើផ្ទះរបស់អ្នកស្ថិតនៅក្នុងតំបន់ដែលមានពណ៌ឬទេ?

ទេ → ទោះបីជាអ្នកមិនរស់នៅក្នុងតំបន់ដែលមានពណ៌ក៏ដោយ ប្រសិនបើតំបន់នោះទាបជាងតំបន់នៅជុំវិញ ឬច្រាំងសមុទ្រ អ្នកគួរមើលព័ត៌មានដែលផ្តល់ជូនដោយអាជ្ញាធរមូលដ្ឋានរបស់អ្នក និងជម្លៀសចេញឱ្យបានត្រឹមត្រូវ។

បាទ/ចាស ↓

តាមគោលការណ៍ * ផ្ទះរបស់អ្នកជាកន្លែងងាយនឹងរងគ្រោះថ្នាក់ ដូច្នេះអ្នកត្រូវជម្លៀសចេញពីទីនោះ។

ករណីលើកលែង →

* ទោះបីជានៅក្នុងតំបន់ដែលមានហានិភ័យទឹកជំនន់ក៏ដោយ អ្នកអាចនៅផ្ទះដោយសុវត្ថិភាព ក្នុងករណីដូចខាងក្រោម៖

1) អ្នកមិនស្ថិតក្នុងតំបន់ដែលមានហានិភ័យខ្ពស់នៃការបាក់រលំផ្ទះ ឬត្រូវបំផ្លាញដោយទឹកជំនន់។
2) ផ្ទះរបស់អ្នកស្ថិតនៅលើដីខ្ពស់ជាងជម្រៅទឹកជំនន់។
3) ទោះបីមានទឹកជំនន់ក៏ដោយ តែអ្នកមានទឹក ចំណីអាហារ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗគ្រប់គ្រាន់រហូតដល់ពេលទឹកជំនន់នោះស្រកទៅវិញ។

* ទោះបីជាអ្នកនៅក្នុងតំបន់ដែលមានហានិភ័យបាក់ដីក៏ដោយ ក៏អ្នកអាចនៅផ្ទះដោយសុវត្ថិភាពបានដែរ ប្រសិនបើអ្នករស់នៅជាន់លើនៃអគារដែលមានសំណង់រឹងមាំ ដូចជា អាផាតមិន ជាដើម។

↓

តើអ្នក និងអ្នកនៅជាមួយត្រូវការពេលដើម្បីជម្លៀសដែរ ឬទេ?

**បាទ/ចាស ↓**

តើអ្នកមានសាច់ញាតិ ឬមិត្តភក្តិណាដែលរស់នៅកន្លែងសុវត្ថិភាព ដែលអាចឱ្យអ្នកស្នាក់នៅជាមួយបានដែរឬទេ?

- បាទ/ចាស → ក្នុងករណីមានការព្រមានកម្រិត 3 អ្នកត្រូវជម្លៀសទៅផ្ទះរបស់សាច់ញាតិ ឬមិត្តភក្តិដែលនៅកន្លែងមានសុវត្ថិភាព (សូមសាកសួរពួកគេអំពីរឿងនេះឱ្យបានមុនពេលមានគ្រោះមហន្តរាយកើតឡើង។)
- ទេ → ក្នុងករណីមានការព្រមានកម្រិត 3 អ្នកត្រូវជម្លៀសទៅជម្រកសម្រាប់ការជម្លៀសដែលបានកំណត់ដោយអាជ្ញាធរមូលដ្ឋានរបស់អ្នក។

**ទេ ↓**

តើអ្នកមានសាច់ញាតិ ឬមិត្តភក្តិណាដែលរស់នៅកន្លែងសុវត្ថិភាព ដែលអាចឱ្យអ្នកស្នាក់នៅជាមួយបានដែរឬទេ?

- បាទ/ចាស → ក្នុងករណីមានការព្រមានកម្រិត 4 អ្នកត្រូវជម្លៀសទៅផ្ទះរបស់សាច់ញាតិ ឬមិត្តភក្តិនៅកន្លែងដែលមានសុវត្ថិភាព។ (សូមសាកសួរពួកគេអំពីរឿងនេះឱ្យបានមុនពេលមានគ្រោះមហន្តរាយកើតឡើង។)
- ទេ → ក្នុងករណីមានការព្រមានកម្រិត 4 អ្នកត្រូវជម្លៀសទៅជម្រកសម្រាប់ការជម្លៀសដែលរៀបចំឡើងដោយរដ្ឋាភិបាលក្នុងតំបន់របស់អ្នក។